# ព្រះរាជក្រម

នស/រកម/០១.៩៩/០១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យ នស/រកត/១១៩៨.៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រមនស/រកម/០១៩៦.១៨ ចុះថ្ងៃទី២៤ ខែមករាឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំអំពី សម្តេចនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី ទទួលបន្ទុក នីតិសម្បទានិងអភិវឌ្ឍន៍ និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសអោយប្រើ

ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ១៩៩៩ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៩ នាសម័យប្រជុំលើកទី១ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ:

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ច្បាប់

# ស្ដីពី

# ហិរញ្ញវត្ថុសំរាប់គ្រប់គ្រងឆ្នាំ ១៩៩៩

# ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

## ស្តីពីចំណូល ចំណាយនៃថវិកាទូទៅរបស់រដ្ឋ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសំរាប់ឆ្នាំ ១៩៩៩ អោយប្រមូលបង់ចូលថវិកាទូទៅរបស់រដ្ឋនូវពន្ធដារ វិភាគទាន អាករ ផលទុននិងចំណូលនានា ព្រមទាំងធ្វើអោយសំរេចនូវអំណោយមូលនិធិបរិភាគនិងធនធានបានមកពីការខ្ចី ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន.................................១.៤៩៥.០០០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ÷

- ចំណូលជាប្រចាំ.................................១.២២០.០០០ លានរៀល
- ចំណូលជាមូលធន.................................២៧៥.០០០ លានរៀល
  + ចំណូលជាមូលធនក្នុងប្រទេស.......................២៥.០០០ លានរៀល
  + ចំណូលជាមូលធនក្រៅប្រទេស.......................២៥០.០០០ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយក្នុងថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានកំណត់ស្មើនឹង..................១.៤៩៥.០០០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ÷

- ចំណាយជាប្រចាំ.................................១.១០០.០០០ លានរៀល
- ចំណាយជាមូលធន.................................៣៩៥.០០០ លានរៀល
  + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស....១៨០.០០០ លានរៀល
    * ដោយមូលនិធិថវិកា...........................១៣០.០០០ លានរៀល
    * ដោយមូលនិធិក្រៅប្រទេសដែលអ្នកផ្តល់អំណោយបានយល់ព្រមជាមុន.... ........................................ ៥០.០០០ លានរៀល
  + ចំណាយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលអនុវត្តក្រៅធនាគារជាតិ...........................២០០.០០០ លានរៀល
  + ចំណាយវិលសងបំណុល...........................១៥.០០០ លានរៀល

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទាន សំរាប់ចំណាយជាប្រចាំរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ត្រូវបានកំណត់ស្មើនឹង.......................១.១០០.០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗនិងទៅតាមប្រភេទនៃថវិកាដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានកម្មវិធីរបស់រដ្ឋ ត្រូវបានបន្តអនុវត្តដូចកម្មវិធីដែលបានកំណត់ដោយច្បាប់ហិរញ្ញវត្ថុឆ្នាំ១៩៩៨ សំរាប់ការគ្រប់គ្រងពីឆ្នាំ១៩៩៨ ដល់ ២០០០ ស្មើនឹង.... ៣.៦៥០.៤៤០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗតាមគំរោងនិងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យានិងឥណទានទូទាត់សំរាប់ចំណាយជាមូលធននៃថវិការដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ត្រូវបានកំណត់ដូចតទៅ ៖

- ឥណទានភ្ជាប់សន្យា.......................................៤៩៥.០០០ លានរៀល
- ឥណទានទូទាត់.............................................៣៩៥.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកដូចតទៅ ៖

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស ៖

- ឥណទានភ្ជាប់សន្យា...................................១៨០.០០០ លានរៀល
- ឥណទានទូទាត់.........................................១៨០.០០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ៖

- ឥណទានភ្ជាប់សន្យា...................................៣០០.០០០ លានរៀល
- ឥណទានទូទាត់.........................................២០០.០០០ លានរៀល

គ. ការវិលសំបំណុលសាធារណៈ ៖

- ឥណទានភ្ជាប់សន្យា...................................១៥.០០០ លានរៀល
- ឥណទានទូទាត់.........................................១៥.០០០ លានរៀល

ឥណទាននេះ ត្រូវបានបែងចែកតាមក្រសួងនីមួយៗនិងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងតាមជំពូកថវិកាដូចមានចែងក្នុងតារាង"ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

# ជំពូកទី ២

# បទប្បញ្ញត្តិ

# ស្តីពីលំនឹងនិងតុល្យភាពនៃថវិកាទូទៅរបស់រដ្ឋ

## មាត្រា ៦.-

តុល្យភាពនៃថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩ ដែលបានរៀបចំឡើងដោយតារាង"ក"ស្តីពីចំណូលថវិកាទូទៅរបស់រដ្ឋនិងតារាង "ខ" ស្តីពីចំណាយថវិកាទូទៅរបស់រដ្ឋ ត្រូវបានបង្ហាញនៅក្នុងតារាងនៃកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋដូចតទៅ ÷

ឯកតា: លានរៀល

| កិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់រដ្ឋ | ចំនួនទឹកប្រាក់ | ចំនួនលើស (+) និងឱនភាព (-) |
|---|---|---|
| I ចំណូលក្នុងប្រទេស | ១.២៤៥.000 | |
| ១.ចំណូលជាប្រចាំ | ១.២២០.000 | |
| ២.ចំណូលជាមូលធនក្នុងប្រទេស (ឯកជនភាវូបនីយកម្ម) | ២៥.000 | |
| II សរុបចំណាយថវិកា [១] | ១.៤៨០.000 | |
| ១. ចំណាយជាប្រចាំ | ១.១០០.000 | |
| ២. ចំណាយជាមូលធន [១] | ៣៨០.000 | |
| - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១៨០.000 | |
| + ដោយមូលនិធិថវិកា | ១៣០.000 | |
| * គំរោងវិនិយោគ (សាងសង់ - ទព្វសម្ភារៈ) | ១០០.000 | |
| * បដិភាគមូលធនចំណែកជាមួយវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ៣០.000 | |
| + ដោយមូលនិធិក្រៅប្រទេសដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | ៥០.000 | |
| - វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ | ២០០.000 | |
| ចំនួនលើសនៃថវិកាជាប្រចាំ | | +១២០.000 |
| និងឱនភាពសរុបនៃថវិកាទូទៅ | | -២៣៥.000 |
| III ហិរញ្ញប្បទាននៃឱនភាព | | +២៣៥.000 |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +២៥០.000 |
| - ជំនួយគាំទ្រថវិកាដែលមានការយល់ព្រមជាមុនពីអ្នកផ្តល់ជំនួយ | | +៥០.000 |
| - ជំនួយគំរោងការ | | +២០០.000 |
| ២. ការរំលស់បំណុល | | -១៥.000 |
| ៣. ហិរញ្ញប្បទានធនាគារ | | 0 |

# ជំពូកទី ៣
## បទប្បញ្ញត្តិស្តីពី ចំណូលថវិកា

**មាត្រា ៧.-**

ត្រូវបានបង្កើតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៩ នូវអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតតាមអត្រាប្រាក់រៀលស្មើនឹងពីរសេនដុល្លារអាមេរិក សំរាប់ប្រេងសាំងមួយលីត្រ និងបួនសេនដុល្លារ អាមេរិក សំរាប់ប្រេងម៉ាស៊ូតមួយលីត្រ ។ ចំណូលពីអាករបន្ថែមនេះ នឹងបំរើអោយហិរញ្ញប្បទាននៃការងារជួសជុលជាប្រចាំនិងជួសជុលខួបនៃផ្លូវជាតិ ផ្លូវខេត្តនិងផ្លូវជនបទ ។

ប្រកាសអន្តរក្រសួងមួយរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងសាធារណការនិងដឹកជញ្ជូន នឹងកំណត់នូវល័ក្ខខ័ណ្ឌបច្ចេកទេសនៃការអនុវត្តវិធានការនេះ ។

# ជំពូកទី ៤
## បទប្បញ្ញត្តិពិសេស
## ស្តីពីការកំណត់ឥណទានថវិកាសំរាប់ក្រសួង ស្ថាប័នថ្មី

**មាត្រា ៨.-**

ឥណទានថវិកាសំរាប់ព្រឹទ្ធសភាមានសរុបចំនួន ៦.៤០០លានរៀល ដែលនឹងត្រូវដកពីឥណទានចំណាយមិនបានគ្រោងទុកនៅក្នុងលេខកូដ ៩៩ ព្រង់ប្រភេទទី៤ នៃតារាង"ខ"។

**មាត្រា ៩.-**

ក្រសួង ស្ថាប័នដូចមានចែងក្នុងតារាង "ខ" ទៅតាមព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ដែលមិនទាន់មានឥណទានថវិកា នឹងត្រូវកំណត់ដោយអនុក្រឹត្យដោយអនុលោមទៅតាមមាត្រា ៤០ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ។

# ជំពូកទី ៥

## បទប្បញ្ញត្តិ

## ស្តីពីការទទួលខុសត្រូវនៃអ្នកគ្រប់គ្រងប្រាក់កាសសាធារណៈ

**មាត្រា ១០.-**

ហាមឃាត់ដាច់ខាតមិនអោយប្រធានស្ថាប័នរដ្ឋបាលនិងអាណាប័កដើមខ្សែព្រមទាំងអាណាប័កផ្ទេរសិទ្ធិចាត់វិធានការទាំងឡាយណាដែលនាំអោយកើនចំណាយលើឥណទានថវិកាទូទៅរបស់រដ្ឋ ដែលពុំមានចែងក្នុងច្បាប់ហិរញ្ញវត្ថុឬច្បាប់ អនុក្រឹត្យនិងបទបញ្ជាដែលមានពីមុនកិច្ចសន្យាចំណាយ ។

**មាត្រា ១១.-**

ដោយអនុវត្តតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ត្រូវបានចាត់ទុកជាកំហុសនៃការគ្រប់គ្រង ដែលបានប្រព្រឹត្តចំពោះរដ្ឋដូចជា ÷

-រាល់អំពើដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៦ នៃច្បាប់នេះ។

-រាល់អំពើដែលបានចុះកិច្ចសន្យាចំណាយលើសឥណទានថវិកាដែលបានអនុម័តដោយរដ្ឋសភា លើកលែងតែឥណទានដែលបានគ្រោងទុកសំរាប់បើកបៀវត្សនិងប្រាក់វិភាជន៍សង្គមសេវាបំណុលនិងសងប្រាក់ខ្ចីដែលបានយល់ព្រមដោយរដ្ឋសភា ព្រមទាំងការបង់វិភាគទានចំពោះអង្គការអន្តរជាតិនានា ។

-រាល់អំពើដែលជាកម្មវត្ថុសំរាប់បង្កើនទឹកប្រាក់ឥណទានថវិកា ដែលបានទទួលការអនុញ្ញាតពីរដ្ឋសភាដោយធនធានពិសេស ក្រៅពីករណីដែលបានកំណត់ដោយច្បាប់និងបទបញ្ជាជាធរមាន និងដោយអនុស្សញ្ញាអន្តរជាតិដែលរដ្ឋសភាបានអនុម័តយល់ព្រម ។

-រាល់កំហុសធ្ងន់ធ្ងរដែលនាំអោយមានការខាតបង់ប្រាក់កាស ដែលហិរញ្ញវត្ថុសាធារណៈទទួលបន្ទុក ។

-រាល់សកម្មភាពគ្រប់គ្រងដែលប្រព្រឹត្តល្មើសនឹងច្បាប់ អនុក្រឹត្យនិងបទបញ្ជាដែលអនុវត្តចំពោះចំណូលនិងចំណាយរបស់រដ្ឋ ។

មាត្រា ១២.-

ដោយអនុលោមទៅតាមមាត្រា៩ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.ន.ស.៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ បានចែងថា "កិច្ចប្រតិបត្តិការជាលក្ខណៈពាណិជ្ជកម្ម ដែលទទួលធ្វើដោយអង្គភាពរបស់រដ្ឋដោយផ្ទាល់ ត្រូវបានដឹកនាំតាមទម្លាប់ប្រើប្រាស់ជាធរមានក្នុងវិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម ក្រោមការត្រួតពិនិត្យរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ" ។

ជាពិសេស កិច្ចសន្យាស្តីពីសម្បទានលើធនធាននៃទ្រព្យសម្បត្តិរដ្ឋ ឬការលក់ផលិតផលនៃអាជីវកម្ម ត្រូវបានសំរេចដោយផ្អែកទៅតាមល័ក្ខខ័ណ្ឌនិងបែបបទជាធរមានទៅ លើទីផ្សារអន្តរជាតិនិងស្របទៅតាមតម្លៃជាក់ស្តែងនៃទីផ្សារ ។

ត្រូវរំលាយចោល នូវរាល់កិច្ចសន្យាដែលទាក់ទងទៅនឹងការលក់ឬការជួលចលនវត្ថុឬអចលនវត្ថុ ដែលជាចំណែកមួយនៃទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងរាល់ការចាត់ចែងប្រើប្រាស់ទ្រព្យសម្បត្តិទាំងឡាយនោះ ក្នុងករណីដែលប្រធានស្ថាប័នបានធ្វើលិខិតកិច្ចរួចហើយ តែអ្នកទិញ អ្នកជួល ឬអ្នកទទួលផលប្រយោជន៍ នៅតែមិនគោរពតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងកិច្ចសន្យា ដូចជាការទូទាត់ថ្លៃលក់ ឬការបង់ថ្លៃឈ្នួលមិនបានទាន់ពេលវេលា ។

ត្រូវរំលាយចោលនូវកិច្ចសន្យាដូចគ្នានេះដែរ ចំពោះសេវាបង់ថ្លៃរបស់រដ្ឋដែលបានចុះកិច្ចសន្យារវាងសេវាសាធារណៈនិងឯកជន ឬអង្គការតតិយ ក្នុងករណីដែលកិច្ចសន្យាទាំងឡាយនោះ ធ្វើអោយប៉ះពាល់ដល់ចំណូលរបស់រដ្ឋ ឬអ្នកទទួលផលប្រយោជន៍មិនបានគោរពតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងកិច្ចសន្យា ។

មាត្រា ១៣.-

ចំណូលទាំងអស់ដែលបានមកពីកិច្ចប្រតិបត្តិការ ដូចមានបញ្ជាក់នៅក្នុងមាត្រា១២ខាងលើ ត្រូវបង់ចូលថវិកាទូទៅរបស់រដ្ឋ ដោយគ្មានកាត់កងនូវចំណូលទាំងនោះ សំរាប់ទូទាត់សោហ៊ុយចំណាយនៃកិច្ចប្រតិបត្តិការនោះឡើយ ។

មាត្រា ១៤.-

ប្រធានស្ថាប័ន អាណាប័កដើមខ្សែនិងអាណាប័កតាមការប្រទានសិទ្ធិព្រមទាំងមន្ត្រីរាជការនិងភ្នាក់ងាររដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់លើការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងជំពូកនេះ ។

អាស្រ័យហេតុនេះប្រធានស្ថាប័ន ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាសស្តីពីការអនុវត្តចំណូល ចំណាយ ថវិការបស់ខ្លួននិងធ្វើរបាយការណ៍ស្តីពីសភាពការណ៍នៃការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋដែលបានប្រគល់អោយខ្លួនកាន់កាប់ជូនគណៈរដ្ឋមន្ត្រីពិនិត្យសំរេចតាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ ដោយបង្ហាញនូវលទ្ធផលដែលសំរេចបាននិងការខ្វះខាត ដែលបានកត់សំគាល់ឃើញ ដោយប្រៀបធៀបទៅនឹងគំរោងនិងគោលដៅព្រមទាំងលើកវិធានការកែលំអនូវការខ្វះខាតទាំងនោះ។

## ជំពូកទី ៦

## បទប្បញ្ញត្តិ

## ស្តីពីការខ្ចីនិងការធានារបស់រដ្ឋ

### មាត្រា ១៥.-

ចំនួនទឹកប្រាក់ជាអតិបរមា ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានអនុញ្ញាតអោយខ្ចីមានកំរិតរហូតដល់ ២០០.០០០.០០០ S.D.R (ពីររយលាន អេសដេអ៊ែ) សំរាប់ឆ្នាំ១៩៩៩ ។

នៅក្នុងល័ក្ខខ័ណ្ឌនេះ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬលើការធានារបស់រដ្ឋ ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកំរិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការទាក់ទងជាមួយធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតអោយលក់ប័ណ្ណរតនាគារក្នុងកំរិតទឹកប្រាក់ចំនួន ៥០.០០០ លានរៀល ដើម្បីបំពាក់នូវឱនភាពថវិកា ឬសំរាប់ដោះស្រាយតំរូវការជាបន្ទាន់ខាងសាច់ប្រាក់។ ល័ក្ខខ័ណ្ឌនៃការលក់ប័ណ្ណរតនាគារនេះ ត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

រាល់ការខ្ចីនិងការធានារបស់រដ្ឋតាមល័ក្ខខ័ណ្ឌពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងថវិកាឆ្នាំ ១៩៩៩ ត្រូវហាមឃាត់ ។

### មាត្រា ១៦.-

មិនអនុញ្ញាតអោយក្រសួងឬស្ថាប័នសាធារណៈចំណុះរដ្ឋណាមួយមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាព ដោះដូរយមូលប័ត្ររយៈពេលវែង មធ្យម ខ្លីឬឥណទានអ្នកផ្គត់ផ្គង់ ឬចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈឬឯកជន ឬចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ឬតាមឆ្នាំ ដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុនិងល័ក្ខខ័ណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

លក្ខខ័ណ្ឌទាំងឡាយនៃកិច្ចប្រតិបត្តិការនីមួយៗ ត្រូវបានកំណត់ដោយអនុក្រឹត្យ យោងតាមរបាយការណ៍របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ស្ដីពីការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះជូនរដ្ឋសភារៀងរាល់ ៦ខែម្ដង ។ ៚

## ជំពូកទី ៧

## បទប្បញ្ញត្តិ

## ស្ដីពីគណនីពិសេសរបស់រតនាគារ ដែលមានឈ្មោះថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ~ គ.ជ.ប"

**មាត្រា ១៧.-**

ទាយជ្ជទាននៃថវិកាសំរាប់ផ្ដល់អោយគណនីពិសេសរបស់រតនាគារ ដែលមានឈ្មោះថា "គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប." ត្រូវបានកំណត់ចំនួន....៦.០០០ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ÷

- ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត..១.០០០ លានរៀល
- ការបោះឆ្នោតមេឃុំ.................................... ៥.០០០ លានរៀល

ក្រៅពីទាយជ្ជទាននៃថវិកាទូទៅរបស់រដ្ឋ ធនធាននៃគណនីពិសេសរបស់រតនាគារ ត្រូវបានបំពេញបន្ថែមដោយ ÷

- អំណោយពីសហគមន៍អន្តរជាតិ
- ចំណូលស្របច្បាប់ផ្សេងៗទៀត

**មាត្រា ១៨.-**

គណនីពិសេសរបស់រតនាគារសំរាប់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបានគ្រប់គ្រងដោយប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅតាមល័ក្ខខ័ណ្ឌ ដែលបានកំណត់ដោយច្បាប់ស្ដីពីការបង្កើតគណនីពិសេស ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខជស/រកម/០៣៩៨/០៤ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ១៩៩៨ ។

**មាត្រា ១៩.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិពីមាត្រា ២៣ ដល់មាត្រា ២៩ នៃច្បាប់ស្ដីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១.នស.៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ការគ្រប់គ្រងនៃគណនីពិសេសរបស់រតនាគារត្រូវបានកំណត់ដោយបទបញ្ញា ។

មាត្រា ២០.-

ចំណូលនិងចំណាយនៃគណនីពិសេសរបស់រតនាគារ ត្រូវបានគ្រោងទុកនិងអនុញ្ញាតនៅក្នុងល័ក្ខខ័ណ្ឌដូចគ្នានៃកិច្ចប្រតិបត្តិការរបស់ថវិការដ្ឋ តែត្រូវស្ថិតនៅក្នុងលក្ខណៈពិសេសដូចតទៅ ÷

១/.សរុបចំណាយដែលបានធ្វើការសន្យាចំណាយឬដែលបានធ្វើបញ្ជាចំណាយលើគណនីពិសេសរបស់រតនាគារមិនត្រូវអោយលើសពីសរុបធនធាននៃគណនីនេះទេ ។

២/.ក្នុងរយៈពេលគ្រប់គ្រង ប្រសិនបើចំណូលនៃគណនីពិសេសរបស់រតនាគារមានចំនួនលើសពីចំណាយដែលបានគ្រោងទុកនោះ ឥណទាននៃគណនីនេះត្រូវបានបន្ថែមតាមកំរិតដែលលើសដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣/.សមតុល្យឥណទាយីនៃគណនីពិសេសរបស់រតនាគារ អាចយោងពីមួយឆ្នាំទៅមួយឆ្នាំទៀតបាន លើកលែងតែមានបទប្បញ្ញត្តិផ្ទុយដែលមានចែងនៅក្នុងច្បាប់ហិរញ្ញវត្ថុ ។

៤/.ហាមមិនអោយកត់ត្រាលើគណនីពិសេសរបស់រតនាគារនូវចំណាយទាំងឡាយណាដែលមិនស្ថិតនៅក្នុងក្របខ័ណ្ឌកម្មវត្ថុរបស់វាមានជាអាទិ ដូចជាប្រាក់បៀវត្សឬប្រាក់បំណាច់ ។

## ជំពូកទី ៨

## បទប្បញ្ញត្តិស្តីពី

## និយតភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ

## ចំណាយថវិកាបន្ថែម សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៨

មាត្រា ២១.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា១៨ និងមាត្រា ៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស.៩៣ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ១៩៩៣ ត្រូវបានយល់ព្រមផ្តល់ឥណទានបន្ថែមដល់ថវិកាទូទៅរបស់រដ្ឋសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ ដូចខាងក្រោមនេះ ÷

-ចំណាយមានលក្ខណៈចាំបាច់នៃបុគ្គលិក ដូចជាប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់វិភាជន៍សង្គម ដែលបានកត់ត្រាទៅលើឥណទានអាចវាយតំលៃបាន (មាត្រា១៨ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ) ។

-អនុក្រឹត្យបុរេប្រទាន (មាត្រា៤៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ) ។

ច្បាប់ទូទាត់នៃថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៨ នឹងត្រូវអនុម័តជាគោលការណ៍និង នឹងកំណត់នូវកំរិតជាអតិបរមានៃកិច្ចប្រតិបត្តិការដែលបានធ្វើឡើងខាងលើនេះ ។

# ជំពូកទី ៩

# បទប្បញ្ញត្តិស្តីពី

# ថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៩

## មាត្រា ២២.-

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ១៨ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ កញ្ចប់ថវិការួមនៃថវិការបស់ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩ ត្រូវបានកំណត់ជាចំណូលនិងចំណាយចំនួន...........................៣៥.០០០ លានរៀល ដែលបានមកពីចំណូលសារពើពន្ធនិងពុំមែនសារពើពន្ធផ្ទាល់របស់ខេត្ត ក្រុងចំនួន.....២០.០០០ លានរៀល និងទទួលការឧបត្ថម្ភពីថវិការដ្ឋចំនួន..................................១៥.០០០ លានរៀល

ការបែងចែកកញ្ចប់ថវិការួមនេះទៅតាមខេត្ត ក្រុងនីមួយៗ ក៏ដូចជាការបែងចែកឥណទាននៅផ្ទៃក្នុងថវិកាទាំងនេះជាជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងតាមប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីក្រសួងមហាផ្ទៃ ។

## មាត្រា ២៣.-

ត្រូវបានអនុញ្ញាតឱ្យខេត្ត ក្រុង ប្រមូលអាករលើមណ្ឌលដែនដីរបស់ខ្លួនសំរាប់បំរើសាធារណៈចំនួន ៣% លើតម្លៃសុរាបៀរនិងបារី ដែលជាផលិតផលមកពីបរទេសហើយលក់ក្នុងដែនដីរបស់ខ្លួន ។

ប្រកាសអន្តរក្រសួងមួយរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមហាផ្ទៃ នឹងកំណត់នូវល័ក្ខខ័ណ្ឌបច្ចេកទេសនៃការអនុវត្តវិធានការនេះ ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២៥.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញ. ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨

ក្នុងព្រះប្រមនាម និងតាមព្រះរាជបញ្ជា

ប្រមុខរដ្ឋស្ដីទី

ព្រះហស្ដលេខា

នរោត្ដម រណឫទ្ធិ

បានបង្គំទូលថ្វាយ

សូមឡាយព្រះហស្ដលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ : ០៧ ចល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ០៩ ខែមករា ឆ្នាំ១៩៩៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ



ឯកតា: លានរៀល

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | បម្រែបម្រួល ថយ | បម្រែបម្រួល កើន |
|---|---|---|---|---|---|---|---|---|
| | | | | សរុបរួមកិច្ចប្រតិបត្តិការថវិកា | 1 445 000 | 1 495 000 | | +50 000 |
| | | | | ក្នុងនោះចំណូលក្នុងស្រុក | 945 000 | 1 245 000 | | +300 000 |
| | | | | សរុបចំណូលជាប្រចាំ | 912 000 | 1 220 000 | | +308 000 |
| | | | | ប្រភេទទី១: ពន្ធ និង អាករ | 665 000 | 853 280 | | +188 280 |
| 10 | | | | ជំពូក១០: ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុន | 57 000 | 81 000 | | +24 000 |
| | 01 | | | ពន្ធលើប្រាក់បៀវត្ស | 10 000 | 15 000 | | +5 000 |
| | 02 | | | ពន្ធលើប្រាក់ចំណេញរបស់រោងចក្រ និង ពាណិជ្ជកម្ម | 43 000 | 60 000 | | +17 000 |
| | | 01 | | សហគ្រាសសាធារណៈ | 7 100 | 8 000 | | +900 |
| | | | 01 | សហគ្រាសមធ្យម | 7 100 | 8 000 | | +900 |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 02 | | សហគ្រាសឯកជន | 35 900 | 52 000 | | +16 100 |
| | | 03 | | ពន្ធកាត់ទុក | | | | |
| | | 04 | | ប្រាក់ចំណេញរបស់សហគ្រាសប្រេងឥន្ធនៈ | | | | |
| | 03 | | | ពន្ធលើការប្រាក់បញ្ញើធនាគារ | | | | |
| | 04 | | | ពន្ធលើផលទុននៃតម្លៃចលនទ្រព្យ | | | | |
| | 05 | | | ពន្ធលើផលទុននៃដីធ្លី . ផ្ទះសម្បែង | 3 000 | 6 000 | | +3 000 |
| | 06 | | | ពន្ធលើតម្លៃលើសអចលនទ្រព្យ | | | | |
| | 07 | | | ពន្ធលើផលទុនកសិកម្ម | | | | |
| | | 01 | | សកម្មភាពព្រៃឈើ | | | | |
| | | 02 | | សកម្មភាពនេសាទ | | | | |
| | | 03 | | អាជីវកម្មកសិកម្មផ្សេងៗទៀត | | | | |
| | 08 | | | ពន្ធដីធ្លីលើដីសល់ទំនេរ (*) | 1 000 | | -1 000 | |
| | 20 | | | ពន្ធផ្សេងៗទៀតលើផលទុន.ប្រាក់ចំណេញនិងកំរៃទុន | | | | |
| 11 | | | | ជំពូក១១: ពន្ធលើបេតិកភណ្ឌ | 4 000 | | -4 000 | |
| | 01 | | | ពន្ធប្រថាប់ត្រា (*) | 4 000 | | -4 000 | |
| | | 01 | | ពន្ធផ្ទេរមតិករវាងអ្នកនៅរស់ | 4 000 | | -4 000 | |
| | | 02 | | ពន្ធផ្ទេរសិទ្ធិពីអ្នកស្លាប់ | | | | |
| 12 | | | | ជំពូក១២: ពន្ធផ្ទៃក្នុងលើទ្រព្យសម្បត្តិនិងសេវា | 223 860 | 326 680 | | +102 820 |
| | 01 | | | អាករលើផលរបរៈ របបផ្ទៃក្នុង | | 16 000 | | +16 000 |
| | | 01 | | សហគ្រាសសាធារណៈ | | | | |
| | | | 01 | សហគ្រាសមធ្យម | | | | |
| | | | 02 | សហគ្រាសខេត្តនានា | | | | |
| | | 02 | | សហគ្រាសឯកជន | | 16 000 | | +16 000 |

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"



## ចំណូលថវិកាចរន្តរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| 12 | 02 | | | អាករលើតំលៃបន្ថែម : របបផ្ទៃក្នុង | 46 600 | 63 000 | | +16 400 |
| | | 01 | | សហគ្រាសសាធារណៈ | 2 700 | 3 000 | | +300 |
| | | 02 | | សហគ្រាសឯកជន | 43 900 | 60 000 | | +16 100 |
| | | | 01 | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | 02 | សហគ្រាសផ្សេងៗ | | | | |
| | 03 | | | ពន្ធប៉ាតង់ (*) | 2 500 | | -2 500 | |
| | 04 | | | អាករពិសេសលើទំនិញមួយចំនួន និងសេវាកម្ម | 94 200 | 80 000 | -14 200 | |
| | | 01 | | របបផ្ទៃក្នុង | 12 000 | 20 000 | | +8 000 |
| | | 02 | | របបនៃការនាំចូល | 82 200 | 60 000 | -22 200 | |
| | | | 01 | សហគ្រាសប្រេងឥន្ធនៈ | | | | |
| | | | 02 | សហគ្រាសផ្សេងៗ | | | | |
| | 05 | | | ពន្ធសណ្ឋាគារ (*) | 560 | | -560 | |
| | 06 | | | ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ (*) | 4 000 | | -4 000 | |
| | 07 | | | អាករស្នាក់នៅ | | | | |
| | 08 | | | អាករលើតំលៃបន្ថែម : របបនាំចូល | 76 000 | 167 680 | | +91 680 |
| | | 01 | | សហគ្រាសប្រេងឥន្ធនៈ | | 55 680 | | +55 680 |
| | | 02 | | សហគ្រាសដទៃទៀត | 76 000 | 112 000 | | +36 000 |
| 13 | | | | ជំពូក១៣: ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | 376 700 | 440 700 | | +64 000 |
| | 01 | | | ពន្ធ និង អាករគយពីការនាំចូល | 362 200 | 433 000 | | +70 800 |
| | | 01 | | ពន្ធគយពីការនាំចូល | 232 900 | 235 000 | | +2 100 |
| | | 02 | | កំរៃយកមុនលើផលិតផលប្រេងកាត | 1 950 | 2 000 | | +50 |
| | | 03 | | កំរៃយកមុនលើការងារគយក្នុងការនាំចូល | 6 250 | 6 000 | -250 | |
| | | 04 | | ពន្ធគយលើផលិតផលប្រេងកាត | 121 100 | 155 000 | | +33 900 |
| | | 05 | | អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតសំរាប់ថែទាំផ្លូវថ្នល់ | | 35 000 | | +35 000 |
| | | 10 | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចូល | | | | |
| | 02 | | | អាករពីការនាំចេញ | 12 300 | 4 700 | -7 600 | |
| | | 01 | | អាករគយពីការនាំចេញ | 12 300 | 4 700 | -7 600 | |
| | | | 01 | អាករលើការនាំឈើចេញ | 3 600 | 2 500 | -1 100 | |
| | | | 02 | អាករលើការនាំកៅស៊ូចេញ | 7 700 | 1 000 | -6 700 | |
| | | | 03 | អាករលើការនាំផលិតផលផ្សេងៗចេញ | 1 000 | 1 200 | | +200 |
| | | 02 | | កំរៃយកមុនលើការងារគយក្នុងការនាំចេញ | | | | |
| | | 10 | | ពន្ធ និង អាករគយផ្សេងៗទៀតពីការនាំចេញ | | | | |
| | 03 | | | ការផាកពិន័យរបស់គយ | 2 200 | 3 000 | | +800 |

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ

ឯកតា: លានរៀល

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | លំអៀង ចុះ | លំអៀង ឡើង |
|---|---|---|---|---|---|---|---|---|
| 14 | | | | ជំពូក១៤: ចំណូលសារពើពន្ធផ្សេងៗទៀត | 3 440 | 4 900 | | +1 460 |
| | 01 | | | ពន្ធតែមប្រិ៍ | 1 000 | 1 900 | | +900 |
| | 02 | | | ពន្ធលើសារលិខិតស៊ីវិល និង តុលាការ | | | | |
| | 03 | | | អាករលើការលេងល្បែង | | | | |
| | 04 | | | ការផាកពិន័យ និង ទោសបញ្ញត្តិសារពើពន្ធ | 2 300 | 3 000 | | +700 |
| | 05 | | | អាករលើយានយន្តនាំចូលដោយផ្ទុយនឹងច្បាប់ | 140 | | -140 | |
| | 06 | | | អាករព្រលានយន្តហោះ | | | | |
| | 10 | | | ចំណូលសារពើពន្ធផ្សេងៗទៀតតាមមុខពន្ធនានា | | | | |
| | | | | **ប្រភេទទី២: ចំណូលពុំមែនសារពើពន្ធ** | 247 000 | 366 720 | | +119 720 |
| 20 | | | | ជំពូក២០: ផលចំនូននៃទ្រព្យសម្បត្តិរដ្ឋ | 126 245 | 169 695 | | +43 450 |
| | 01 | | | ផលនេសាទ | 11 600 | 15 000 | | +3 400 |
| | 02 | | | ផលព្រៃឈើ | 46 500 | 73 000 | | +26 500 |
| | 03 | | | ផលចំនូនបានមកពីសហគ្រាសសាធារណៈ | 50 095 | 47 580 | -2 515 | |
| | | 01 | | ការផ្តល់ភាគចំណេញសហគ្រាស | 21 026 | 8 210 | -12 816 | |
| | | | 01 | សហគ្រាសមជ្ឈិម | 16 530 | 8 210 | -8 320 | |
| | | | 02 | សហគ្រាសខេត្តនានា | 4 496 | | -4 496 | |
| | | 02 | | ការបង់ប្រាក់រំលស់ឡើងវិញ | 4 016 | 2 190 | -1 826 | |
| | | | 01 | សហគ្រាសមជ្ឈិម | 4 015 | 2 190 | -1 825 | |
| | | | 02 | សហគ្រាសខេត្តនានា | 1 | | -1 | |
| | | 03 | | ចំនួនលើសនៃចំនូនចល័ត | | | | |
| | | 04 | | សេវាកម្មនៃការគ្រប់គ្រងការរបស់សហគ្រាសសាធារណៈ | | | | |
| | | 05 | | ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ | 1 | | -1 | |
| | | 06 | | ផលចំនូនរបស់អាកាសចរណ៍ស៊ីវិល | 19 000 | 27 100 | | +8 100 |
| | | 07 | | ផលចំនូននៃសកម្មភាពកាពយន្ត | 1 | | -1 | |
| | | 08 | | ផលចំនូននៃសកម្មភាពទេសចរណ៍ | 4 387 | 9 800 | | +5 413 |
| | | 09 | | ការលក់សិក្សារបរិក្ខា | 983 | | -983 | |
| | | 10 | | ការជួលសិក្សារបរិក្ខា | 9 | | -9 | |
| | | 11 | | ផលនៃការជីកជញ្ជូនទំនិញ | 273 | | -273 | |
| | | 12 | | ផលនៃប្រតិបត្តិការពាណិជ្ជកម្ម | 4 | | -4 | |
| | | 13 | | ការផ្គត់ផ្គង់អគ្គិសនីនៅតាមខេត្តនានា (*) | 98 | | -98 | |
| | | 14 | | ផលទុកនៃរោងចក្រទឹក (*) | 35 | | -35 | |
| | | 20 | | ផលចំនូនផ្សេងៗទៀតរបស់សហគ្រាសសាធារណៈ | 262 | 280 | | +18 |

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"

## ចំណូលថវិកាចរន្តរបស់រដ្ឋ



ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខណ្ឌ និង អនុកថាខណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខណ្ឌ | អនុកថាខណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | លំអៀង ថយ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| 20 | 04 | | | កំរៃយកមុនក្នុងសម្បទានទ្រព្យសម្បត្តិរដ្ឋ | 1 512 | 11 500 | | +9 988 |
| | | 01 | | សម្បទានពីប្រេងកាត | 320 | 400 | | +80 |
| | | 02 | | សម្បទានពិធី | 1 192 | 1 100 | -92 | |
| | | 10 | | សម្បទានផ្សេងៗទៀត | | 10 000 | | +10 000 |
| | 05 | | | ពន្ធលើការកាន់កាប់កម្មសិទ្ធិសាធារណៈ (*) | 5 114 | | -5 114 | |
| | | 01 | | ផលនៃការជួលកន្លែងលក់ដូរក្នុងទីផ្សារ | 3 343 | | -3 343 | |
| | | 02 | | ពន្ធចំណតរថយន្ត | 547 | | -547 | |
| | | 03 | | ពន្ធកំពង់ចំលង | 957 | | -957 | |
| | | 04 | | ពន្ធកន្លែងលក់ដោយការដេញថ្លៃ | 267 | | -267 | |
| | 06 | | | ការជួលអចលនវត្ថុ | 11 377 | 22 515 | | +11 138 |
| | 07 | | | ផលពីការលក់ផ្ទៃគយ | | 100 | | +100 |
| | 08 | | | ផលបានមកពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈដើរ | | | | |
| | 09 | | | ផលពីការលក់ចលនវត្ថុនិងអគាររបស់រដ្ឋ | | | | |
| | 20 | | | ផលផ្សេងៗទៀតពីទ្រព្យសម្បត្តិរដ្ឋ | 47 | | -47 | |
| 21 | | | | ជំពូក២១: ចំណូលផ្សេងៗទៀតពុំមែនសារពើពន្ធ | 120 755 | 197 025 | | +76 270 |
| | 01 | | | ផលខុទ្ទប្រៃសណីយ៍ និង ទូរគមនាគមន៍ | 100 198 | 161 000 | | +60 802 |
| | 02 | | | ផលខុទ្ទវិទ្យុ ទូរទស្សន៍ ការផ្សាយ | 450 | 420 | -30 | |
| | 03 | | | ចំណូលនៃសេវាកម្មសាធារណៈ | 17 788 | 32 875 | | +15 087 |
| | | 01 | | កំរៃនៃការថែទាំ | 17 | 18 | | +1 |
| | | 02 | | ការលក់សំភារៈសិក្សា | | | | |
| | | 03 | | អាករនៃស្ថានទូត | 7 940 | 19 450 | | +11 510 |
| | | 04 | | ផលខុទ្ទនៃសកម្មភាពវប្បធម៌ | 222 | 290 | | +68 |
| | | 05 | | ពន្ធលើអាជ្ញាប័ណ្ណនាំឈើចេញ | 1 700 | 2 700 | | +1 000 |
| | | 06 | | ការត្រួតពិនិត្យគុណភាពផលិតផល | 875 | 4 202 | | +3 327 |
| | | 07 | | ពន្ធលើការបង្កើតសហគ្រាស | 170 | 300 | | +130 |
| | | 08 | | ការបង់ប្រាក់ធានាសំរាប់បង្កើតសហគ្រាស | | | | |
| | | 09 | | ការលក់ឯកសារគយ | | 20 | | +20 |
| | | 10 | | លតាបត្រ និង លិខិតបោះពុម្ពផ្សេងៗរបស់គយ | 1 450 | 1 500 | | +50 |
| | | 11 | | ឯកសារផ្សេងៗទៀត | 3 070 | 3 255 | | +185 |
| | | 12 | | ការលក់ឯកសារ និង លិខិតបោះពុម្ពរបស់ពន្ធដារ | 40 | 100 | | +60 |
| | | 13 | | ផលនៃការលក់ផ្លាកលេខ | 442 | 500 | | +58 |
| | | 14 | | ពន្ធលើការធ្វើអត្តសញ្ញាណប័ណ្ណជាតិ | 1 542 | | -1 542 | |
| | | 15 | | អាករចុះបញ្ជីគណៈបក្សនយោបាយ | | | | |
| | | 30 | | ចំណូលផ្សេងៗទៀតរបស់សេវាកម្មសាធារណៈ | 320 | 540 | | +2[illegible] |

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"

## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | តំរៀប ចុះ | តំរៀប ឡើង |
|---|---|---|---|---|---|---|---|---|
| 21 | 04 | | | ប្រាក់ចំណេញរតនាគារ និង ការប្រាក់ផ្សេងៗ | | | | |
| | 05 | | | ចំណូលក្រៅសារពើពន្ធរបស់ខេត្តនានា (*) | 1 079 | | -1 079 | |
| | 06 | | | ប្រាក់ចំណេញធនាគារជាតិ | | | | |
| | 20 | | | ចំណូលផ្សេងៗក្រៅពីសារពើពន្ធ | 1 240 | 2 730 | | +1 490 |
| | | | | **សរុបចំណូលជាមូលធន** | 533 000 | 275 000 | -258 000 | |
| | | | | **ប្រភេទទីពា: ចំណូលជាមូលធន** | 533 000 | 275 000 | -258 000 | |
| 30 | | | | ជំពូក៣០: ចំណូលផ្ទៃក្នុងជាមូលធន | 21 000 | 25 000 | | +4 000 |
| | 01 | | | ការលក់ទ្រព្យសម្បត្តិនៃមូលធនថេរ | | | | |
| | 02 | | | ការលក់ដីធ្លី | | | | |
| | 03 | | | ការលក់ទ្រព្យសកម្មអរូបីយ និង ហិរញ្ញវត្ថុ | | | | |
| | 04 | | | ផលឯកជនភាវូបនីយកម្ម | 21 000 | 25 000 | | +4 000 |
| | 15 | | | ចំណូលពីការវិនិយោគក្នុងប្រទេស | | | | |
| 31 | | | | ជំពូក៣១: អំណោយពីបរទេស | 400 000 | 50 000 | -350 000 | |
| | 01 | | | ជំនួយមនុស្សធម៌ | | | | |
| | | 01 | | ...................................... | | | | |
| | | 02 | | ...................................... | | | | |
| | 02 | | | មូលនិធិបដិភាគ | 100 000 | 50 000 | -50 000 | |
| | | 01 | | ជប៉ុន | 18 000 | | -18 000 | |
| | | 02 | | អាល្លឺម៉ង់ | 1 400 | | -1 400 | |
| | | 03 | | បែលហ្ស៊ិក | | | | |
| | | 04 | | ចក្រភពអង់គ្លេស | | | | |
| | | 05 | | បារាំង | | | | |
| | | 06 | | អង្គការសហប្រជាជាតិ | | | | |
| | | 07 | | អ៊ីតាលី | | | | |
| | | 08 | | ស៊ុយអែដ | | | | |
| | | 30 | | ផ្សេងៗទៀត | 80 600 | | -80 600 | |
| | 03 | | | អំណោយផ្សេងៗទៀតពីបរទេស | 300 000 | | -300 000 | |
| | | 01 | | ជប៉ុន | | | | |
| | | 02 | | សហរដ្ឋអាមេរិក | | | | |
| | | 03 | | អង្គការសហប្រជាជាតិ | | | | |
| | | 04 | | បារាំង | | | | |
| | | 05 | | អូស្ត្រាលី | | | | |
| | | 06 | | ស៊ុយអែដ | | | | |

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ក"



## ចំណូលថវិកាទូទៅរបស់រដ្ឋ

ការប្រមាណចំណូលតាមប្រភេទ ជំពូក ប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ

ឯកតា: លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | ការរាយមុខចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៨ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | លំអៀង ខ្វះ | លំអៀង លើស |
|---|---|---|---|---|---|---|---|---|
| 31 | 03 | 07 | | ចប្រាក់អប់ផ្សេង | | | | |
| | | 08 | | អាល្វីម៉ង់ | | | | |
| | | 09 | | សហគមន៍អឺរ៉ុប | | | | |
| | | 30 | | ផ្សេងៗទៀត | | | | |
| | 04 | | | អំណោយដោយខ្សែក្រសិកាប់រំលស់បំណុល | | | | |
| 32 | | | | ជំពូក៣២: ប្រាក់ទ្រព្យសម្បត្តិបានមកពីការខ្ចីបុល | 112 000 | 200 000 | | +88 000 |
| | 01 | | | ប្រាក់ខ្ចីផ្ទៃក្នុង | 12 000 | | -12 000 | |
| | | 01 | | ប្រាក់ខ្ចីផ្ទៃក្នុងបានមកពីប្រព័ន្ធធនាគារ | 12 000 | | -12 000 | |
| | | | 01 | .................................... | | | | |
| | | | 02 | .................................... | | | | |
| | | 02 | | ប្រាក់ខ្ចីផ្ទៃក្នុងផ្សេងៗទៀត | | | | |
| | | | 01 | .................................... | | | | |
| | | | 02 | .................................... | | | | |
| | 02 | | | ប្រាក់ខ្ចីពីបរទេស | 100 000 | 200 000 | | +100 000 |
| | | 01 | | ប្រាក់ខ្ចីពីបរទេសបានមកពីអង្គការអន្តរជាតិនានា | 100 000 | 200 000 | | +100 000 |
| | | | 01 | ធនាគារពិភពលោក | 100 000 | 90 000 | -10 000 | |
| | | | | មូលនិធិបរិភាគ | | | | |
| | | | | គំរោងខ្ចី | 100 000 | 90 000 | -10 000 | |
| | | | 02 | ធនាគារអាស៊ីសំរាប់អភិវឌ្ឍន៍ | | 110 000 | | +110 000 |
| | | | | មូលនិធិបរិភាគ | | | | |
| | | | | គំរោងខ្ចី | | 110 000 | | +110 000 |
| | | | 03 | .................................... | | | | |
| | | | | .................................... | | | | |
| | | | | .................................... | | | | |
| | | 02 | | ប្រាក់ខ្ចីពីបរទេសបានមកពីរដ្ឋាភិបាល និង អង្គការទំនាក់ទំនង | | | | |
| | | | 01 | .................................... | | | | |
| | | | 02 | .................................... | | | | |
| | | 03 | | ប្រាក់ខ្ចីពីបរទេសបានមកពីអង្គការឯកជននានា | | | | |
| | | | 01 | .................................... | | | | |
| | | | 02 | .................................... | | | | |

(*) ចំណូលសារពើពន្ធ និង ចំណូលពុំមែនសារពើពន្ធដែលបានផ្ទេរអោយទៅការខេត្ត ក្រុង ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ។

# ការគ្រប់គ្រងឆ្នាំ ១៩៩៩

## តារាង "ខ"

## ចំណាយថវិកាចរន្តរបស់រដ្ឋ

ការបូកសរុបចំណាយតាមក្រសួង និង តាមប្រភេទ

ឯកតា: លានរៀល

